# ការបំពេញ និង ការផ្ញើត្រឡប់មកវិញនូវទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត

## លក្ខណៈសម្បត្តិក្នុងការចុះឈ្មោះបោះឆ្នោត៖

- ជាពលរដ្ឋអាមេរិកាំង និង ជាអ្នករស់នៅរដ្ឋ California
- មានអាយុយ៉ាងតិច 18 ឆ្នាំឡើង នៅថ្ងៃបោះឆ្នោត ឬ មុនថ្ងៃបោះឆ្នោត
- នៅពេលបច្ចុប្បន្ននេះ មិនត្រូវបានជាប់ពន្ធនាគាររដ្ឋ ឬ ជាប់ពន្ធនាគារសហព័ន្ធសម្រាប់ការផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ ហើយនិង
- នៅពេលបច្ចុប្បន្ននេះមិនត្រូវបានរកឃើញថាមានបញ្ហាផ្នែកខាងផ្លូវចិត្តដែលគ្មានសមត្ថភាពក្នុងការបោះឆ្នោតដោយតុលាការទេ

## ការបំពេញទម្រង់បែបបទ

ដើម្បីជៀសវាងការពន្យារពេលដំណើរការទម្រង់បែបបទរបស់អ្នក ត្រូវប្រាកដថា ទម្រង់បែបបទរបស់អ្នកអោយមានសុពលភាពយកជាការបាន និង បានទទួលយកដោយបំពេញផ្នែកដិត ខាងក្រោម។ ការទុកផ្នែកខាងក្រោមឱ្យនៅទទេអាចបណ្តាលឱ្យមានការពន្យារពេល ដំណើរការទម្រង់បែបបទបស់អ្នក៖

**ផ្នែក 1 - *លក្ខខណ្ឌ៖** ត្រូវប្រាកដថា គូសឆីកប្រអប់ទាំងពីរ ប្រសិនបើវាត្រូវបានអនុវត្ត សំណុំបែបបទរបស់អ្នកមិនអាចត្រូវបានដំណើរការទេ ប្រសិនបើប្រអប់សញ្ជាតិអាមេរិក មិនត្រូវបានគូសឆីក។

**ផ្នែក 2 - *ឈ្មោះស្របច្បាប់៖** យើងសូមណែនាំឱ្យអ្នកចុះឈ្មោះដើម្បីបោះឆ្នោតដោយប្រើឈ្មោះដូចគ្នានឹងការបង្ហាញនៅលើប័ណ្ណបើកបររបស់អ្នក។

**ផ្នែក 3 - អត្តសញ្ញាណប័ណ្ណ៖** ប្រសិនបើអ្នកមានប័ណ្ណបើកបរ CA /លេខអត្តសញ្ញាណប័ណ្ណ និង/ឬ លេខសន្តិសុខសង្គមរបស់អ្នក សូមសរសេរព័ត៌មាននោះនៅទីនេះ។ ប្រសិនបើអ្នកមិនមានទេ អ្នកមិនចាំបាច់បំពេញវាទេ។

**ផ្នែក 4 - *អាសយដ្ឋានដែលខ្ញុំរស់នៅ៖** អ្នកត្រូវតែផ្តល់អាសយដ្ឋានផ្លូវសម្រាប់អាសយដ្ឋានដែលអ្នករស់នៅ។ ប្រសិនបើអ្នកមិនមានអាសយដ្ឋានផ្លូវទេ អ្នកអាចផ្តល់ការពិពណ៌នាយ៉ាងច្បាស់អំពីកន្លែងដែលអ្នករស់នៅ។ រួមមានបញ្ចូលរផ្លូវឆ្លងកាត់ ផ្លូវជាតិ ។ល។

រាប់បញ្ចូលទាំងអាផាតមិន យូនីត ទំហំ ឬ លេខអគារ និង/ឬ លិខិត ប្រសិនបើមានបញ្ជាក់អំពីអាសយដ្ឋានរបស់អ្នក។

ប្រអប់សំបុត្រ ប្រអប់ទម្លាក់សំបុត្រមិនអាចត្រូវបានប្រើជាអាសយដ្ឋានលំនៅដ្ឋានទេ។

**ផ្នែក 5 - អាសយដ្ឋានដែលខ្ញុំបានទទួលសំបុត្រ៖** ប្រសិនបើអាសយដ្ឋានទទួលសំបុត្ររបស់អ្នកខុសពីអាសយដ្ឋានលំនៅដ្ឋានរបស់អ្នក សូមផ្តល់អាសយដ្ឋានទទួលសំបុត្ររបស់អ្នក។ អាសយដ្ឋានណាមួយដែលអាចត្រូវបានប្រើជាអាសយដ្ឋានទទួលសំបុត្រដោយរួមបញ្ចូលប្រអប់សំបុត្រ។ ប្រអប់ ឬ ការទម្លាក់សំបុត្រ។

**ផ្នែក 6 - ប្រវត្តិនៃការចុះឈ្មោះ៖** បំពេញផ្នែកប្រវត្តិចុះឈ្មោះដែលអ្នកធ្លាប់បានចុះឈ្មោះពីមុនមក។

**ផ្នែក 7 - ការបោះឆ្នោតតាមសំបុត្រ៖** នៅក្រោមក្រឹត្យច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត អ្នកបោះឆ្នោតគ្រប់រូបនឹងត្រូវបានផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រដោយដោយមិនបាច់ដាក់ការស្នើសុំ។ ទោះយ៉ាងណាក៏ដោយ អ្នកមិនចាំបាច់ទាមទារអោយប្រើវានោះទេ។ អ្នកបោះឆ្នោតគ្រប់រូបក៏មានជម្រើសក្នុងការទៅមណ្ឌលបោះឆ្នោត និង បោះឆ្នោតដោយផ្ទាល់ខ្លួនឯងជំនួសវិញ។

*ទម្រង់បែបបទរបស់អ្នកមិនអាចដំណើរការបានទេ ប្រសិនបើអ្នកមិនបានបំពេញនៅលើចន្លោះដែលទុកចោលអោយនៅទទេ ទាំងនេះ។

**ផ្នែក 8 - គណបក្សនយោបាយអាទិភាព៖** ប្រសិនបើអ្នកមិនចង់ជ្រើសរើសគណបក្សនយោបាយណាមួយ អ្នកអាចគូសធីកនៅលើប្រអប់ "គ្មានគណបក្ស/គ្មាន" ។ ការដែលមិនគូសនេះ នឹងបង្ហាញគណបក្សនយោបាយអាទិភាពរបស់អ្នកដោយស្វ័យប្រវត្តិទៅជា គ្មានគណបក្សអាទិភាព។

**ផ្នែក 9 - ព័ត៌មានអ្នកបោះឆ្នោតគឺជាជម្រើសស្រេចចិត្តរបស់អ្នកបោះឆ្នោត៖** ព័ត៌មាននៅក្នុងផ្នែកនេះគ្រាន់តែជាជម្រើសប៉ុណ្ណោះ។

**ផ្នែក 10 - *លិខិតបញ្ជាក់៖** ចុះហត្ថលេខា ហើយ ដាក់ថ្ងៃទីនៅលើទម្រង់បែបបទរបស់អ្នក។ ទម្រង់បែបបទរបស់អ្នកត្រូវតែចុះហត្ថលេខាដើម្បីឱ្យមានដំណើរការ និងការអនុម័ត។

## ការផ្ញើទម្រង់បែបបទចុះឈ្មោះត្រឡប់មកវិញ

- ហែកចេញ ហើយរក្សាទុកផ្នែកខាងក្រោមនៃទម្រង់បែបបទដែលជាបង្កាន់ដៃរបស់អ្នក។ នៅពេលបានដំណើរការ និងអនុម័ត នោះអ្នកនឹងទទួលបានប័ណ្ណជូនដំណឹងអ្នកបោះឆ្នោតតាមសំបុត្រ។
- ទម្រង់បែបបទអាចត្រូវបានផ្ញើតាមសំបុត្រ ហើយ ត្រូវតែអោយបានបិទតែមប្រៃសណីយ៍បានដាក់ស្លាកបោះត្រាសម្គាល់តាមថ្ងៃ ទីផុតកំណត់នៃការចុះឈ្មោះ
- អ្នកអាចផ្ញើទម្រង់បែបបទនេះត្រឡប់មកវិញដោយផ្ទាល់នៅការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ទោះយ៉ាងណា ការផ្ញើតាមសំបុត្រគឺត្រូវបានលើកទឹកចិត្ត។
- ប្រសិនបើអ្នកកំពុងផ្ញើទម្រង់នេះត្រឡប់មកវិញក្នុងនាមជាអ្នកបោះឆ្នោត នោះអ្នកត្រូវតែផ្ញើត្រឡប់មកវិញក្នុងរយៈពេល 3 ថ្ងៃ បន្ទាប់ពីទទួលបាន

## ថ្ងៃផុតកំណត់នៃការចុះឈ្មោះតាមក្រដាស ហើយនិង តាមអ៊ិនធឺណិត

- ពលរដ្ឋមានសិទ្ធិដែលត្រូវការចុះឈ្មោះ ឬ ចុះឈ្មោះបោះឆ្នោតសារឡើងវិញ ក្នុងរយៈពេល 14 ថ្ងៃ នៃការបោះឆ្នោត អាចបំពេញការចុះឈ្មោះបោះឆ្នោតតាមលក្ខខណ្ឌ និង បោះឆ្នោតនៅការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ឬ នៅតាមមណ្ឌលបោះឆ្នោតណាមួយក៏បាន។

**ការចុះឈ្មោះអ្នកបោះឆ្នោតនៅតាម អ៊ិនធឺរណែត នៅរដ្ឋ California**
អ្នកក៏អាចចុះឈ្មោះបោះឆ្នោតនៅតាម
registertovote.ca.gov

Santa Clara County Registrar of Voters
VOTER'S CHOICE
your new voting experience

ក្រឹត្យច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត (VCA) ត្រូវបានអនុវត្តនៅ ខោនធី Santa Clara (SCC) ក្នុងឆ្នាំ 2020 ។ ស្ថិតនៅក្រោម VCA, អ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុង ខោនធី SCC អាចចូលទៅទីតាំងមណ្ឌលបោះឆ្នោត ក៏ដូចជាការិយាល័យរបស់មន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ដើម្បីទម្លាក់សន្លឹកឆ្នោត ដាក់សន្លឹកឆ្នោតដោយផ្ញើតាមសំបុត្រ ទទួលបានសន្លឹកឆ្នោតជំនួស ចុះឈ្មោះបោះឆ្នោត ទទួលបានភាសា ឬ ក៏ ជំនួយលទ្ធភាពចេញចូល និង ទទួលបានសេវាកម្មណាមួយដែលមានជាធម្មតាសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត។

**ជម្រើសរបស់អ្នកបោះឆ្នោត គឺជាជម្រើសរបស់អ្នក**

ស្វែងយល់បន្ថែមតាម sccvote.org/voterschoice
ឬ ទូរស័ព្ទទៅលេខ (866) 430-VOTE
សម្រាប់ព័ត៌មានបន្ថែម។

ស្កេនកូដ QR® ជាមួយស្មាតហ្វូនរបស់អ្នក
ដើម្បីមើលវីដេអូពីរបៀបចុះឈ្មោះបោះឆ្នោត។